# ព្រឹត្តិបត្រទី២ ខែសីហា ឆ្នាំ២០២២



## ផ្លូវនៅឆ្ងាយ

ផលប៉ះពាល់នៃជំងឺរាតត្បាតបានពន្យារពេលការអនុវត្តសកម្មភាពមួយចំនួនរបស់គម្រោង។ ផលប៉ះពាល់មិនស៊ីមេទ្រីនេះបានបង្កើតឱ្យមានពេលវេលាដ៏លំបាកមួយ មិនត្រឹមតែលំបាកសម្រាប់ការបញ្ចប់កិច្ចការដែលមានបំណងត្រូវបញ្ចប់នៅនឹងកន្លែងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលំបាកចំពោះការសម្រេចបានភារកិច្ចផ្សេងទៀតដែលតម្រូវឱ្យធ្វើរួមគ្នាដោយសមាជិកទាំងអស់នៃភាពជាដៃគូផងដែរ។ ជាពិសេសសកម្មភាពខាងក្រោមត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ៖ ដំបូងឡើយ ការបង្កើតបណ្ដាញភាគីពាក់ព័ន្ធមួយ ដើម្បីធ្វើការរួមគ្នាលើវគ្គសិក្សាសារព័ត៌មាន SDG នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាអាស៊ី។ លើសពីនេះ ការចុះទៅសិក្សាស្រាវជ្រាវត្រូវតែកំណត់ពេលវេលាឡើងវិញ ហើយចុងក្រោយ ការកើតមានរលកជំងឺរាតត្បាតជាថ្មី បានរារាំងដល់ការដាក់បញ្ចូលដ៏សមស្របនៃវគ្គសិក្សាទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ដែលជាហេតុនាំឱ្យមានការពន្យារពេលសកម្មភាពពាក់ព័ន្ធផ្សេងទៀត។

## ការវិវត្តចុងក្រោយបំផុត

សម្រាប់ហេតុផលខាងលើ ពេលវេលាអនុវត្តរបស់គម្រោងត្រូវបានពន្យារពេលរហូតដល់ **ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣** ដោយមានការយល់ព្រមពីទីភ្នាក់ងារប្រតិបត្តិការអប់រំ និងវប្បធម៌អឺរ៉ុប (EACEA) នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។ សំណើសុំពន្យារពេលនេះធ្វើឡើងនៅថ្ងៃទី២៥ ខែកុម្ភៈ រួមជាមួយនឹងផែនការការងារដែលត្រូវបានកែប្រែមួយ។ ការពន្យារពេលនេះនឹងអនុញ្ញាតឱ្យមានភាពបត់បែនមួយចំនួន និងការផ្លាស់ប្តូរបន្តិចបន្តួចក្នុងរយៈពេលកំណត់ដែលបានកែសម្រួលនេះ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវនៃការអនុវត្តគម្រោង។



**នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២** សន្និសីទតាមអ៊ីនធឺណិតក្រោមប្រធានបទ “កិច្ចសហប្រតិបត្តិការម៉ាឡេស៊ី-អឺរ៉ុបក្នុងការអប់រំឧត្តមសិក្សា” ត្រូវបានរៀបចំធ្វើឡើង។ សន្និសីទនេះមានគោលបំណងបង្រួបបង្រួមគ្រឹះស្ថានឧត្តមសិក្សា ជាប្រយោជន៍ដើម្បីលើកកម្ពស់ការចែករំលែកចំណេះដឹង និង

Co-funded by the Erasmus+ Programme of the European Union

ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការបោះពុម្ពនេះមិនបង្កើតឱ្យមានការយល់ព្រមណាមួយលើខ្លឹមសារនេះឡើយ ដែលខ្លឹមសារនេះឆ្លុះបញ្ចាំងទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវលើការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងនូវព័ត៌មានដែលមានក្នុងការបោះពុម្ពផ្សាយនេះទេ។

ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ចំពោះការរាយការណ៍ព័ត៌មាន។ អ្នកតំណាងមួយចំនួនបានចូលរួមក្នុងព្រឹត្តិការណ៍នេះ ដែលភាគច្រើនមកពីគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសម៉ាឡេស៊ី។



**នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២** កិច្ចប្រជុំភាពជាដៃគូមួយត្រូវបានរៀបចំធ្វើឡើងតាមអ៊ីនធឺណិត ដែលក្នុងអំឡុងពេលកិច្ចប្រជុំនោះ ផែនការការងារដែលត្រូវបានធ្វើបច្ចុប្បន្នភាពមួយត្រូវបានដាក់ចេញដោយអ្នកសម្របសម្រួល។ ទន្ទឹមនឹងនេះដែរ ទិសដៅរបស់គម្រោងសម្រាប់រយៈពេលពី ៣ ទៅ ៤ ខែខាងក្រោមត្រូវបានពិភាក្សា ជាមួយនឹងការផ្តល់វគ្គសិក្សាថ្មី (ដែលនឹងអនុញ្ញាតឱ្យដាក់ដំណើរការសាកល្បងនៅខែសីហា ឬខែកញ្ញា ឆ្នាំ២០២២) ដែលជាអាទិភាពកំពូល។ ភាពជាដៃគូនេះក៏បានឯកភាពលើយុទ្ធសាស្ត្រអនុវត្តទាក់ទងនឹងដំណើរទស្សនកិច្ចសិក្សានាពេលខាងមុខនៅខេត្តបាត់ដំបង ប្រទេសកម្ពុជា (ក្នុងអំឡុងខែធ្នូ ឆ្នាំ២០២២) នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី (ក្នុងអំឡុងខែមិថុនា/កក្កដា ឆ្នាំ២០២៣) និងនៅទីក្រុងនីងបូ ប្រទេសចិន (ក្នុងអំឡុងខែតុលា/ខែវិច្ឆិកា ឆ្នាំ២០២៣)។

**ចាប់ពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២** សាលា SDGs Journalism Summer School បានដំណើរការនៅសាកលវិទ្យាល័យ Nottingham Ningbo China (UNNC)។ ក្នុងអំឡុងវគ្គសិក្សានេះ និស្សិតនៅសាកលវិទ្យាល័យ UNNC សរុបចំនួន ២៤នាក់ត្រូវបានផ្តល់ឱកាសឱ្យចូលរួមក្នុងការបង្រៀន ដំណើរទស្សនកិច្ចណែនាំ និងសិក្ខាសាលា។ គោលបំណងរបស់ពួកគេគឺដើម្បីជួយសិស្សឱ្យស្វែងយល់អំពីសារៈសំខាន់នៃតួនាទីរបស់សារព័ត៌មានក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលបានកំណត់សម្រាប់របៀបវារៈឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិ។




លើសពីនេះទៀត និស្សិតទាំងនេះមានឱកាសទទួលបានបទពិសោធក្នុងការបង្កើតរបាយការណ៍ពហុប្រព័ន្ធផ្សព្វផ្សាយ (Multi-media) និងបទបង្ហាញអំពីរឿងរ៉ាវ SDG ពហុប្រព័ន្ធផ្សព្វផ្សាយ ដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ការបំពុលអាកាសធាតុ

Co-funded by the Erasmus+ Programme of the European Union

ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការបោះពុម្ពនេះមិនបង្កើតឱ្យមានការយល់ព្រមណាមួយលើខ្លឹមសារនេះឡើយ ដែលខ្លឹមសារនេះឆ្លុះបញ្ចាំងទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវលើការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងនូវព័ត៌មានដែលមានក្នុងការបោះពុម្ពផ្សាយនេះទេ។

និងអាហារ និងកាកសំណល់ប្លាស្ទិក។




**នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២** កិច្ចប្រជុំភាពជាដៃគូតាមអ៊ីនធឺណិតមួយត្រូវបានរៀបចំធ្វើឡើង។ អ្នកសម្របសម្រួលបានសង្កត់ធ្ងន់លើតម្រូវការក្នុងការរៀបចំ *វគ្គបណ្តុះបណ្តាលបុគ្គលិក* នាពេលខាងមុខដែលជាដំណាក់កាលដ៏សំខាន់មួយនៅក្នុងវដ្តជីវិតរបស់គម្រោង។ ការសម្របសម្រួល និងការផ្តល់វគ្គបណ្តុះបណ្តាលនេះ ត្រូវបានចាត់តាំងឱ្យ “សាកលវិទ្យាល័យ UNIVERSITATEA LUCIAN BLAGA DIN SIBIU” (LBUS), “សាលវិទ្យាល័យ Universiti Utara Malaysia” (UUM) និង “សាកលវិទ្យាល័យភូមិន្ទភ្នំពេញ” (RUPP) ជាអ្នករៀបចំ។ សកម្មភាពដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយវគ្គបណ្តុះបណ្តាលអំពីការរាយការណ៍សារព័ត៌មានសាកល្បងត្រូវបានប្រគល់ទៅឱ្យ “សាកលវិទ្យាល័យ Nottingham Ningbo China” (UNNC), “សាលវិទ្យាល័យ UNIVERSITATEA LUCIAN BLAGA DIN SIBIU” (LBUS) និង “សាលវិទ្យាល័យ Shenzhen Polytechnic” (SZPT)។

ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ គឺជាថ្ងៃដែលមានការចាប់ផ្តើមដោយជោគជ័យនូវវគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណិត ដែលនឹងបន្តធ្វើឡើងរហូតដល់ថ្ងៃទី៥ ខែសីហា។ វគ្គបណ្តុះបណ្តាលអនឡាញចំនួនបួន (៤) ត្រូវបានធ្វើឡើងដោយជោគជ័យដោយគ្រូបណ្តុះបណ្តាលមកពីសាកលវិទ្យាល័យ UUM និងសាកលវិទ្យាល័យ LBUS ។ **នៅថ្ងៃទី៨ ខែកក្កដា** ម៉ូឌុលទី១ ស្តីពី “របៀបវារៈនៃពាក្យ និង SDG” ត្រូវបានចែកចាយ។ **នៅថ្ងៃទី១៥ ខែកក្កដា** វគ្គបណ្តុះបណ្តាលតាម អ៊ីនធឺណិតលើកទីពីរសម្រាប់ម៉ូឌុលទី២ ស្តីពី “និរន្តរភាព” ត្រូវបានបញ្ចប់។ **នៅថ្ងៃទី២២ ខែកក្កដា** វគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណិតលើកទី៣ សម្រាប់ម៉ូឌុលទី៣ ស្តីពី “សារព័ត៌មាន និងបច្ចេកទេសរៀបរាប់រឿង” ត្រូវបានធ្វើឡើង។ ជាចុងក្រោយ វគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណិតលើកទី៤ ដែលធ្វើឡើង**នៅថ្ងៃទី២៩ ខែកក្កដា** បង្រៀនអំពីម៉ូឌុលទី៤ ស្តីពី “ការអនុវត្ត”។




## ផ្លូវខាងមុខ

**នៅថ្ងៃទី៥ ខែសីហា** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) ក្រោមកិច្ចសហការជាមួយ Novel Group ត្រូវបានចាត់តាំងឱ្យធ្វើបទបង្ហាញអំពីភ្លែតហ្វមអនឡាញរបស់ គម្រោង។ សាកលវិទ្យាល័យ RUPP នឹងធ្វើបទ

Co-funded by the Erasmus+ Programme of the European Union

ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការបោះពុម្ពនេះមិនបង្កើតឱ្យមានការយល់ព្រមណាមួយលើខ្លឹមសារនេះឡើយ ដែលខ្លឹមសារនេះឆ្លុះបញ្ចាំងទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវលើការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងនូវព័ត៌មានដែលមានក្នុងការបោះពុម្ពផ្សាយនេះទេ។

SDGs | Journalism Reporting.

បង្ហាញផ្នែកទីមួយ ដែលនឹងរួមមាន ទស្សនៈនានាអំពី "ការរៀនសូត្រតាមប្រព័ន្ធឌីជីថលដែលមានប្រយោជន៍ និងឧបករណ៍គរុកោសល្យ"។ ផ្នែកទីពីរ ដែលនឹងពិភាក្សាអំពីលក្ខណៈ និងមុខងារនៃភ្លែតហ្វមវែបដែលត្រូវបានបង្កើតឡើង នឹងត្រូវធ្វើបទបង្ហាញដោយ Novel Group។

**ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២** ដំណើរទស្សនកិច្ចសិក្សាលើកទី១ នឹងប្រព្រឹត្តទៅនៅខេត្តបាត់ដំបង ប្រទេសកម្ពុជា។ កាលវិភាគសកម្មភាពនៅតែស្ថិតក្រោមការកំណត់និយមន័យ និងការពិភាក្សានៅឡើយ។

**ការរៀបចំ និងបើកវគ្គបណ្តុះបណ្តាល សាកល្បង។** ឯកសារសិក្សានឹងត្រូវបាន សរសេរដោយប្រើការផ្តល់យោបល់ដែលធ្វើឡើងដោយសមាជិកនៃសម្ព័ន្ធដៃគូ។ សម្ភារសិក្សាពីរប្រភេទផ្សេងគ្នា ដែលមួយប្រភេទសម្រាប់ការបង្រៀននៅសាលា និងមួយទៀតសម្រាប់ការរៀនពីចម្ងាយតាមអ៊ីនធឺណិត នឹងត្រូវបានបង្កើតឡើង។

**សូមចូលទៅកាន់គេហទំព័ររបស់យើង៖** www.journalism-reporting.eu

ជួបជាមួយក្រុមការងារ "SDGsJR"

Co-funded by the Erasmus+ Programme of the European Union

ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការបោះពុម្ពនេះមិនបង្កើតឱ្យមានការយល់ព្រមណាមួយលើខ្លឹមសារនេះឡើយ ដែលខ្លឹមសារនេះឆ្លុះបញ្ចាំងទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវលើការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងនូវព័ត៌មានដែលមានក្នុងការបោះពុម្ពផ្សាយនេះទេ។